ព្រះរាជបណ្ណាល័យកម្ពុជា

# កម្ពុជសុរិយា

## សៀវភៅចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

## ឆ្នាំគម្រប់បី

ខែ ២

ក្រុងភ្នំពេញ
រោងពុម្ពរាជការ គូវែរណឺម៉ង់
គ្រិ. ឆ្នាំ ១៩៣០
ពុ.ស ២៤៧២

អ្នកទទួលខុសត្រូវ ជុំ-ម៉ៅ

# បញ្ជីរឿង


ទំព័រ

១- សេចក្ដីអធិប្បាយអំពីរូបសម្រិទ្ធ ១ ដែលមានមុខ ៤ នឹងដៃ ៤ អ្នកស្រី ស៊ុយ-សាន ការប៉ុវ៉ែស្សអធិប្បាយ . . . . . . . ៤៥

២- មិលិន្ទបញ្ហា ព្រះគ្រូវិមលបញ្ញា អ៊ុម ស៊ុរ អាចារ្យនៅព្រះរាជបណ្ណាល័យ កម្ពុជា ប្រែចេញពីបាលី (ត) . . . . .

៣- គតិលោក ឬ ច្បាប់ទូន្មានខ្លួន ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ រៀបរៀង (ត) (មិលិន្ទបញ្ហា និង គតិលោក មិនមានចុះផ្សាយទេ ព្រោះមានបោះពុម្ពជាសៀវភៅហើយ) . . . . . . . .

៤- រឿងមហាភារតយុទ្ធ ព្រះមហាពិទូរ ក្រសេម គន្ថរចនបណ្ឌិតនៅព្រះរាជបណ្ណាល័យ ប្រែចេញពីសៀមមកជាភាសាខ្មែរ (ត) . . . ៤៧

# រូបសម្រឹទ្ធិមុខបួននិងដៃបួន
# បានមកពីវត្តក្ដី ខេត្តកំពង់ស្ពឺ

## ម៉ាដឺម៉ូអាហ្សែល ការប៉ុឡេស អធិប្បាយ

### ក្រុមការ ជុំ - ម៉ៅ ប្រែជាភាសាខ្មែរ

---

រូបនេះ កម្ពស់ ៧ សង្ទីមែត្រ គេធ្វើតំណាងព្រះ១អង្គ មានព្រះកេត្រ ៤ ហើយមានម្កុដលើង១បង្ហើតខ្ពស់ឡើង នៅក្បាំងនៃមុខមួយ ៗ មានរចនាជាអ៊ី១នៅចំកណ្ដាល ទឹងថាជាក្អែក១ក៏បាន ទឹងថាជាកែវ១ក៏បាន មុខទាំងឡាយនេះ ឃ្លាតពីគ្នាពី១ទៅ ១ តែដោយមានទំហូដែលជាប់នៅត្រចៀក ឯមុខទី ៤ ឬមុខដែលនៅចំពីខាងក្រោយលុបអស់គ្មានសល់ ។ ឯ កំណាត់រូបខាងលើនោះ ឥតមានគ្របដណ្ដប់ដោយសំពត់អ្វីឡើយ ហើយមានខ្សែក ២ ជាន់ ខ្សែនោះមានរចនាជាក្បាច់នៅខាងមុខ រូបនេះមានពាក់កងនៅកំភួនដៃនឹងកដៃ មានខ្សែ១ខ្សែពាក់លើស្មាឆ្វេង ព័ទ្ធទៀងចុះទៅឯចង្កេះស្ដាំ ប៉ុន្តែខ្សែនេះទឹងថាជាផ្នត់សំពត់ដែលគ្របលើស្មាឆ្វេងក៏បាន ។

គេអាចនឹងស្គាល់ជាច្បាស់ប្រាកដណាស់ អំពីគ្រឿងប្រដាប់ដែលកាន់នៅដៃខាងលើទាំង ២ គឺដៃស្ដាំកាន់ផ្គាំ ដៃឆ្វេងកាន់សៀវភៅ នៅក្នុងដៃខាងក្រោមទាំង ២ ដែលដាក់នៅលើជង្គង់ គេអាចនឹងស្គាល់បាន

ថា នៅដៃខាងឆ្វេងគឺកដារ ហើយអាចនឹងស្មានបានថានៅដៃខាងស្ដាំគឺផ្កាឈូក១ នៅខាងក្រោយមើលឃើញខ្សែក្រវាត់តែសំពត់ជាប់នៅចង្កេះ ៗ

តើរូបនេះឯងមានដើមកំណើតនៅទីណា ក្នុងគ្រានេះយើងមិនអាចបញ្ជាក់បានឡើយ តើអំពីកាលសម័យណា ប្រហែលជាក្នុងរវាងកាលសម័យព្រះពុទ្ធសករាជពី ១៣០០ ទៅ ១៥០០ ឆ្នាំ តើរូបនេះឯងគេធ្វើតំណាងព្រះអ្វី ទំនងប្រហែលជាលោកេស្វរៈ ព្រោះគ្រឿងប្រដាប់ដែលកាន់នៅដៃ មុខ ៤ និងក្អែកដែលនៅកណ្ដាលមានភាពសណ្ឋានដូចមុខ ៤ នៅនគរវត្ត ដែលសុទ្ធតែជារូបលោកេស្វរៈទាំងអស់ ៗ

ប៉ុន្តែប្រសិនបើជាគេទុករូបនេះជារូបខាងព្រាហ្មណ៍សាសនា នោះគេត្រូវទុកក្អែកកណ្ដាល ក្បាំងមុខ ជាគ្រឿងរចនាវិញ ទុកផ្នត់សំពត់ជាខ្សែសំគាល់ព្រាហ្មណ៍ ទុកគ្រឿងប្រដាប់ដែលកាន់នៅដៃខាងក្រោមទាំង ២ជាកន្ទីរសម្រាប់តាបស និងជាបាច់ស្បូវក្លាំងឬស្លាបព្រាឈើសម្រាប់ដួសសប្បិ ៗ ឃើញថាជាការពិបាកដោយក្រៃលែងណាស់ ដែលនឹងកំណត់ដើមកំណើតនឹងឲ្យឈ្មោះដល់រូបដែលសឹករលុបគ្រឿងសម្គាល់អស់ ៗ

រូបនេះឯងជារបស់មានប្រយោជន៍ប្រសើរ ១ ក្នុងបំណោមរូបរបស់ព្រះរាជបណ្ណាល័យទាំងប៉ុន្មាន ហើយមានតម្លៃក្នុងការរចនាទៀត ព្រោះរាងរៅសក្តិសមល្អ ហើយធ្វើដោយផ្ចិតផ្ចង់ផង ៗ

ស៊ុយសាន-ការប៉ីឡែស

# រឿងមហាភារតយុទ្ធ

ព្រះមហាពិទូរ ក្រសេម គន្ថរចនបណ្ឌិត នៅព្រះរាជបណ្ណាល័យកម្ពុជា ប្រែពីភាសាសៀម

[៣]

---

នៅទីព្រះរាជវាំង និងតាមផ្លូវថ្នល់ ដោតករវែត ឆ័ត្រទង់ព្រោង ព្រាយ នៅមាត់ទ្វារនីមួយៗ ក៏សុទ្ធតែប្រដាប់ដោយគ្រឿងសម្ដែងសេចក្ដីបដិសណ្ឋារក្រេកអរទទួល នឹងជាទីប្រដាប់កិត្តិយសនៃខត្តិយរាជ លុះបាណ្ឌវកុមារចូលមកដល់ទីគាល់ព្រះចៅធ្ឫតរាស្ត្រ ក៏ស្ដេចចុះពីរាជបល្ល័ង្ក ត្រង់មកឧបក្អួយរាល់អង្គតាមលំដាប់ បាណ្ឌវកុមារក៏ក្រាបទៀបបាទយុគលទទួលពរ ព្រះរាជិនី នឹងពួកនារីដែលមានបណ្ដាសក្តិខ្ពស់ក្នុងរាជសំណាក់ក៏ដូចគ្នា នាំគ្នាទៅទទួលទ្រោបទី ទ្រោបទីក៏ក្រាបចុះទៀបបាទ សម្ដែងសេចក្ដីគោរពតាមបែបសុភាពស្ត្រី មើលទៅកិរិយាមារយាទនិងរូបឆោមរបស់នាងជាទីត្រូវព្រះហឫទ័យ ព្រះរាជវង្សានុវង្សក្សត្រីជាយ៉ាងក្រៃពេក ពួកប្រយូរវង្សគ្រប់ៗ អង្គ ក៏ស្រឡាញ់ពេញហឫទ័យនិងសរសើរគុណសម្បត្តិរបស់នាងជាអនេកប្រការ ។

ការដុះផ្សារវាងព្រះញាតិដែលឃ្លាតគ្នាទៅ បានសះជាប្រមព្រៀងឡើងវិញដោយប្រការដូចនេះ មធុរកថារបស់ព្រះចៅធ្ឫតរាស្ត្រ ក៏ត្រាស់ប្រលោមលួងឲ្យសាមគ្គីគ្នាទៅវិញជាច្រើនប្រការ ទោះបីមិនស្និទ្ធស្នាលដូចអំ-ពីដើមក៏គង់ក្ដី ទ្រង់ប្រាស្រ័យនឹងយុធិស្ឋិរជាក្មួយប្រុសថា សេចក្ដីអាក់ចិត្តរវាងក្មួយនិងមា វេលានេះរាប់ថាគ្មានហើយ តទៅខាងមុខសុំឲ្យមេត្រី

រវាងរាជត្រកូលកុរុទ័ងបណ្ដាគប្បីមានជល់គ្នា ដែលជាព្រះញាតិដីដូនមួយគ្នា មាសុខចិត្តបែងផែនដីឲ្យក្មួយពាក់កណ្ដាល ក្មួយទឹងតាំងរាជធានីឡើងថ្មីទៀតនៅខណ្ឌវបថ ឬនៅទីដទៃក៏បាន ហើយចូលគ្រប់គ្រងអា-ណាចក្ររបស់ក្មួយឲ្យជាសុខសម្រាន្តកិយេប្រាយសចុះ ។

អាស្រ័យហេតុនេះ រាជអាណាចក្រក្រហស្តិនបូរ ទើបត្រូវញែកជាពីរភាគ ទុរយោធន៍រើសយកខេត្រផ្សេង ៗ ក្នុងទិសបូព៌ ដែលសម្បូណ៌ទៅដោយផលាផលជាសិទ្ធិរបស់ខ្លួន យុធិស្ឋិរបានភាគខាងលើ ដែលជាទីអារញ្ញប្រទេស តោងកាប់គាស់រានសាងជារាជធានីទីក្រុងឡើង ។

# ភាគទី ៥

## ឥន្ទ្របថរដ្ឋ រាជអាណាចក្រថ្មី

តមក បាណ្ឌវក្សត្រិយ៍ទាំង ៥ អង្គ ក៏នាំគ្នាទៅសាងរាជធានីទីក្រុងថ្មីនៅខណ្ឌវបថ ផ្ដើមកសាងកាប់គាស់ឈើព្រៃ ចូកចាំងជម្រះដី ទីទួលឲ្យរាបទាបស្មើផ្ទៃ ស្រេចហើយទើបសាងព្រះរាជមន្ទីរ ព្រមទៅដោយកំផែងដ៏វិចិត្រ ហាក់ដូចជាទេពនិម្មិតក៏ប្រហែលគ្នា តាំងនៅឆ្នេរទន្លេយមុនាខ្ពស់ត្រដឹមស្កឹមស្កៃ លេចកំពូលប្រូងប្រាងប្រាង្គលលៃគ្រប់ទៅលើទន្លេ ជីកស្រះជីកកូទឹងបន្ទាយជ្រលងអូរ សម្រាប់បង្ហូរទឹកចេញចូលតាមត្រូវការ ធ្វើទាំងឧទ្យានសួនផ្កា និងសួនច្បារផលាផលជុំវិញព្រះរាជមន្ទីរសុទ្ធសឹងតែព្រឹក្សាលតាជាតិដ៏មានផ្លែផ្កា គួរជាទីទស្សនា

នៃអ្នកដែលបានទៅយល់ មានជ្រលងជងទឹកដ៏ថ្លា ហូរអំពីទន្លេយមុ-នាចូលទៅក្នុងឧទ្យាន ដក់ទៅក្នុងល្អាងដ៏មាននៅក្នុងសួនជាអន្លើ ៗ សម្រាប់ចិញ្ចឹមឈើព្រឹក្សាលតាជាតិឲ្យស្រស់ខ្ចីជានិច្ច មានហ្វូងរមាំងព្រាយទន្សាយក្តាន់ជាដើម ដើររកស៊ីស្មៅក្នុងត្រណុំឧទ្យានដ៏ខៀវខ្ចីវិស័យដូចជាព្រំដ៏វិចិត្រ មានហ្វូងបក្សីនវជាតិ ហិចហើរត្រៀលត្នាត់ចាប់ព្រឹក្សា មយូរាដើរកែក្រាយក្បែរគុម្ពឈើ ខ្លះទំលើមែកឈើស្រសាស់ស្លាបក្ងោក ប៉ោលគេកន្ទុរសេកចាប យាស់យំកេបកាបតាមភាសា សកុណាធ្លាស់ឆ្លើយដំព្រៃ ត្រូវនឹងសម្លេងរៃយំឆាំង ៗ ឮហើយភាន់ភាំងឈានឈប់ឈរស្តាប់សព្ទបក្សី ។

អាស្រ័យលោកសង្ការគាក់គែងឡើង ដោយធម្មតាឯងខ្លះ អា-ស្រ័យវិទ្យារបស់បុគ្គលរចនាឡើងខ្លះ តោមលំអរនៃធម្មជាតិទាំងឡាយនោះ ទើបប្រមូលមកមានព្រមនៅទីនោះ ជាទីសម្រាន្តរម្យរីករាយនៃអ្នកដ៏ជាម្ចាស់ លុះសាងស្រេចបាណ្ឌវក្សត្រិយ៍ក៏ស្តេចឡើងគង់រាំងថ្មីតាមវិធីបុរាណសម្មតនាមថា ឥន្ទ្របថ ព្រោះល្អប្រហែលរម្យស្ថានក្នុងត្រៃត្រឹង្សភពរបស់សម្តេចអម្រិន្ទ្រាធិរាជ ។

គ្រានោះអ្នកនគរព្រមគ្នាអញ្ជើញយុធិស្ឋិរឡើងសោយរាជសម្បត្តិនាក្រុងឥន្ទ្របថ ដោយម្ចប់ពោធិសក្ការរបស់ព្រះអគ្គិ ប្រទេសក៏ស្តុកស្តម្ភសម្បូណ៌ឡើងគ្រប់យ៉ាង ប្រជារាស្ត្រនៅជាសុខក្សេមក្សាន្តសព្វទិវារាត្រីឥតមានភិតភ័យដោយរឿងអ្វី ទ្រង់ផ្សាយព្រះរាជានុភាពរាតបេញទៅ

បន្តិចម្តង ៗ ឡើយ ៗ ទៅ ទាល់តែឥន្ទ្របទរដ្ឋធំទូលាយជាងកំណត់ដើម មិនមែនតែមានដែនដីធំប៉ុណ្ណោះ នៅមានកម្លាំងរេហ៍ពលដ៏ក្លាហានជាអនេក ទ្រង់នៅអំណាចឥស្សរភាពក្នុងផ្លូវរដ្ឋប្រសាសនយ៉ាងស្រួច លុះព្រះយុធិស្ឋិរឃើញថា ការព្រះនគរបានចម្រើនធំទូលាយដល់ខ្នាតហើយ ការគ្រប់គ្រងក៏ខ្ជាប់ខ្ជួនបរិបូណ៌គ្រប់យ៉ាងហើយ ទ្រង់នៅព្រះតេជានុភាព និងព្រះកិត្តិយសជាមហារាជា ទ្រង់ប្រាថ្នានិងធ្វើពិធីសួយយ័ជនកម៌ ការបូជាមហារាជ ដើម្បីប្រកាសឥស្សរភាពរបស់ទ្រង់ អ្នកជាមហារាជា ឲ្យប្រាកដទៅក្នុងពួកក្សត្រិនោះដែរគ្រងនគរតូចតាចនៅជិតខាងរាជរដ្ឋសីមា ទើបទ្រង់ប្រើអនុជាទាំង ៤ អង្គ ឲ្យយាត្រាទៅជាន់ដែនប្រទេសរាជជិតខាងអម្បាលនោះ ដើម្បីប្រកាសឥស្សរភាពជាក្សត្រិយ៍ធំលើនានាប្រទេសរាជ ពួកប្រទេសរាជដែលព្រមចុះចូល ក៏បានអញ្ជើញមកប្រជុំក្នុងពិធី សួយយ័ជនកម៌ ចំណែកឯប្រទេសដែលរឹងទទឹង ប្ដតស៊ូ ក៏ត្រូវប្រហារខ្ទេចទៅ ដែនដីក៏ត្រូវរឹបយកមករួមជាអាណាចក្ររបស់មហារាជាឥន្ទ្របថ ។

រាជសួយពិធីគ្រានេះ កើតផលសម្រេចយ៉ាងធំក្នុងផ្លូវរដ្ឋប្រសាសនោបាយ ធ្វើឲ្យព្រះ យុធិស្ឋិរ តាំងមាំទៅក្នុងរាជសម្បត្តិ បានផ្សាយរាជសម្បត្តិអាណាចក្រគ្របទៅលើសាមន្តរាជតូចធំទាំងឡាយ ជាបច្ច័យឲ្យព្រះអង្គមានមិត្រមេត្រី និងមហារាជាក្នុងប្រទេសឥណ្ឌាភាគលើជា

ច្រើនអន្លើ ហើយជួយជញ្ជូនព្រះតេជានុភាពនិងកិត្តិប្រវត្តិឲ្យខ្ចរខ្ចាយទៅក្នុងនានាប្រទេស ។

ស្រេចការពិធីនេះហើយមិនយូរប៉ុន្មាន ទុរយោធន៍ព្រមដោយពងបៈ-វិពារ និងព្រះសកុនិ ជាបិតុលាធិកដនៃគណៈក្សត្រិយ៍គោរព ស្តេចទៅប្រពាតឯនគរឥន្ទ្របថ ដែលខុសប្រាហ៍ស្តេចទៅតាំងម៉ោះ ដោយព្រះហឫទ័យពេញទៅដោយសេចក្តីឫស្សា ជាងទៅសម្តែងសេចក្តីត្រេកអរក្នុងរឿងសាងកដជាទីថ្មី សារពើដែលទ្រង់បានឃើញ សារពើដែលទ្រង់បានស្តាប់ សារពើដែលទ្រង់បានប្រាព្ធទៅដល់ សុទ្ធតែជាគ្រឿងញុញញុកឲ្យកើតសេចក្តីឫស្សានិងអាឃាដឡើង ទីងមើលភូមិប្រទេសឥន្ទ្របថក៏ល្អឯកអស្ចារ្យ ទីងមើលទៅមុខមាត់ប្រជាជន ក៏រីករាយត្រេកត្រអាលទៅដោយសេចក្តីសុខសម្រាន្ត ព្រះរាជាណាចក្រនេះរឿងសម្បូណ៌ព្រមះពេញទៅដោយរបស់ដ៏មានតម្លៃ ជាទីគួរមើលគួរឃើញរបស់ដែលអស្ចារ្យបំផុតក៏គឺព្រះរាជវាំង នុតវិស័យទុរយោធន៍នឹងប្រទះឃើញក្នុងទីដទៃ ការដែលទៅក្រុងឥន្ទ្របថគ្រានេះ សះភ្លឹតមើលអាកប្បកិរិយាក៏ដូចជាគៀនតែងប្រ-ទេសតាំងក្នុង ដែលគេតែងនាំទៅកាន់នានាប្រទេសតាមសព្វមួយដង តែក្នុងហឫទ័យទុរយោធន៍ ពេញទៅដោយសេចក្តីក្តៅក្រហាយដ៏លើសលន់ តែទៅជាយកំណាចដែលមកឃើញរបស់ចំឡែកអស្ចារ្យដូចនេះ ជាទីដឹកត្អូកឲ្យមើលទាល់តែភ្លើន វេលាដែលទ្រង់យាងទតមហាស្ថាន ដូនកាលព្រះសិរទៅប៉ះនឹងជញ្ជាំង ដែលខាត់រលោងឡើងស្រមោលដូចជាកញ្ចក់

ខ្លាំង ក្នុងកាលដែលទ្រង់ព្យាយាមនឹងយាងទៅត្រង់នោះ ដោយស្មានថាជាទីបន្ទោះដល់ទៅ ១ កន្លែងទៀត ខណៈកាលទ្រង់យាងពីបន្ទប់១ចូលទៅបន្ទប់១ទៀត ទៅប្រទះកន្លែងបន្ទប់ទឹក ប្រហ៊ុ(១) ដែលកំពុងខ្ពុលបញ្ចេញសុគន្ធសារ មានអាការដូចជាគ្រាប់ភ្លៀងដ៏ល្អិត ធ្លាក់ចុះអំពីពិដានស្រោចទទឹកគ្រឿងទ្រង់ជោក ដល់ទៅមួយកន្លែងទៀតទ្រង់លាត់អន្ទើញព្រះភូសា ដោយសម្គាល់ថាជាណ្តូងទឹក តែទឹកនោះជាផ្លូវដើរជារបស់វិការដោយថ្មីដៃជាងធ្វើបញ្ឆោតទុក ។

តែសេចក្តីពិត មិនមែនជាពួកបាណ្ឌវក្សត្រិយ៍បំណងនឹងធ្វើលេងឬធ្វើដើម្បីឲ្យទ្រង់អាម៉ាស់មុខនោះទេ តែទុរយោធន៍ឯងមានសន្តានចិត្តជាបុគ្គលពាល ក៏បេះតែចាំរើសយករឿងរញ៉ិករញ៉ុកបន្តិចបន្តួចនេះពូតឡើងជាដុំ ព្រោះប្រទះត្រង់រឿងដែលទ្រង់ល្ងើលកាលណា ពួកបាណ្ឌវក៏ទ្រង់សម្រួលកាលនោះ ដោយអត់មិនបានទ្រង់សម្រួលយឹក ៗ តាមគេទជាញាតិស្និទ្ធមិនមែនជាទ្រង់សម្រួលក្អាកក្អាយយ៉ាងកញ្ឆាះគេនោះទេ ទុរយោធន៍នឹកអៀនខ្មាសក៏រករឿងចងអាឃាដទៅឯង ប្រញាប់ស្តេចចេញមកពីទីក្រុងឥន្ទ្របថ លុះមកដល់ព្រះនគរ ក៏ទ្រង់លើកយករឿងដែលបរិតក្កនោះមកប្រារព្ធនឹងសកុនីជាបិតុលាថា ៖

ទ្រង់សកុនី ខ្ញុំឈឺចិត្តណាស់ ពួកបាណ្ឌវជាមនុស្សអាក្រក់សល់សែន បានត្រៀមការទុកធ្វើបាបខ្ញុំ ដោយឧបាយដ៏លៃបខាយ មាន

---

១- ទឹកដាំស៊ើ ។

ទេវតាជាប្រធានព្រះគុណ គំនិតរបស់គេគិតតែមើលឆ្ងាយខ្ញុំប៉ុណ្ណោះ សេចក្តីប្រមាទមើលឆ្ងាយអស់នេះ ចត់ល្ងីងជាងខ្ទឹមឈើដែលល្ងីងណាស់ទៅទៀត វាតាំងចិត្តមើលឆ្ងាយប្រមាទគ្នាមែនៗ ហេតុនោះពួកវាទើបដើរតាមខ្ញុំស្រេរ ដូចជាឆ្កែតាមដើងដំរី ដើម្បីនឹងបានឃើញហេតុកេទដែលវាក្មេងធ្វើទកគឺវាចាំមើលតែខ្ញុំដែលភ្លាត់ដួលគិតដួលតួង អាវឿងដួលវាក៏សំខាន់ណាស់ដែរ ដូចជាធ្លាក់អំពីទីខ្ពស់រលាត់ដៃជើងទៅអស់ក្រែល ព្រះរាជហឫទ័យព្រះជនកខ្ញុំសោតក៏ត្រជាក់ល្ហិម ដោយដកការបៀតបៀន ឥឡូវនេះទ្រង់មិនអាចនឹងត្រិះរិះកែបញ្ហាដែលជំពាក់ទាក់ទិននឹងជ្រៅសុខុមនេះបាន តែខនេះអស់យើងពល់គ្នាដែលជាកូនប្រុសមានដៃមានជើងគ្រប់បរិបូណ៌មិនត្រូវមើលបំណាំឬទ្រង់យល់ដូចម្ដេច ព្រះជនលោកជកណាស់ហើយ ទ្រង់ចាំតែស្តាប់ទីប្រឹក្សាយ៉ាងអព្យាក្រិត ទើបឯទីប្រឹក្សានោះសោតខិងទុកចិត្តវា ក៏ដូចជាទុកចិត្តអសិរពិស អាពួកចង្រៃវាលក់ម្ចាស់ឯងទ្រម វាទូលណែនាំឲ្យព្រះជនក បែងព្រះរាជអាណាចក្ររបស់ខ្ញុំឲ្យទៅពួកបាណ្ឌវពាក់កណ្ដាលដែលគេមិនមានសិទ្ធិ ឬមុខក្រសួងនិងត្រូវបានសោះឡើយ ព្រះជនកលោកគំនិតស្រាលណាស់ បើប្រ-សិនជាត្រូវនិរទេសចេញអំពីក្រះរាជវាំងទៅម្តង ប្រហែលជានឹងទ្រង់ជ្រាបព្រះអង្គថា ខុនេះទោសព្រោះបំពុឹមអសិរពិសទុក ១ ក្រោលធំនោះឯងខ្ញុំពោលមកទាំងនេះព្រោះជាការផ្ទុកផ្ដាល់ខ្លួន ព្រះបិតុលាក៏ឃើញនឹងព្រះនេត្រស្រាប់ហើយថា ពួកអធម៌សេនាបតីរបស់យើង បានកើបកោយព្រះ

រាជទ្រព្យអំពីព្រះឃ្លាំង ផ្ដុកផ្ដេរចាក់ទៅឲ្យពួកបាណ្ឌវប៉ុន្មាន ខ្ញុំមិនមែនជាកូនស្រី និងមកដេកយំហ៊ឹៗ តាមសភាពជាអ្នកចិត្តទន់នោះទេ ខ្ញុំបំជាកូនប្រុសខ្ញុំនឹងច្បាំងទាល់តែផុតដង្ហើមអស្សាសបស្សាសជាទីបំផុត តែបង់ក្របែលអាពួកចង្រៃអប្បលក្សណ៍អស់នេះជាមុន ហើយនឹងឆាប់ទៅក៏តាមការចុះ ខ្ញុំគ្នាមើលឃើញថាកម្លាំងកងទ័ពរបស់យើងក្នុងវេលានេះទន់ណាស់ មិនល្មមនឹងធ្វើការដណ្ដើមជ័យកណ្ដាលយុទ្ធភូមិជាមួយនឹងសឹកព្រោះវាមានកម្លាំងរឹងរិទ្ធិ មានទាំងពួកសម្ពន្ធមិត្រជិតខាងជំនួយច្រើនផ្លូវឯសេចក្ដីលំអរុងរឿងក្នុងប្រទេសរបស់គេ ជាគ្រឿងធ្វើឲ្យរកាំក្នុងភ្នែកខ្ញុំណាស់ ស្មើដូចជាកន្ទុយថ្ងូទដែលកើតក្នុងភ្នែក ខ្ញុំបង់តែស្លាប់ទៅជាជាងរស់នៅដោយសេចក្ដីអប្បយសដូចនេះ ខ្ញុំនឹងមានអាយុរស់នៅ សូម្បីដូចជីវិតក្អែកក៏តាមការចុះ ។

សកុនិ អង្គុយស្ដាប់រឿងផ្ដេសផ្ដាសនេះរឿយទៅ មិនមានឆ្លើយឆ្លងថាអ្វីដល់មួយម៉ាត់ ទាល់តែទុរយោធន៍ពោលចប់ចុះ គេជាខ្ញុំរាជការធ្លាប់តែប្រចុបប្រចែងម្ចាស់ ស្ទាត់ក្នុងការអង្គុយស្ដាប់ស្ងៀមៗ នឹងស្ទាត់ក្នុងវិធីប្រតិបត្តិមិនឲ្យទាស់អធ្យាស្រ័យម្ចាស់ កាលឃើញទុរយោធន៍ខ្ញាល់ខឹងពួកព្រះញាតិណាស់ណា ជាឱកាសនឹងបំពេញឡើងឲ្យដល់ការគេក៏ក្អេរពិសដាក់បន្ថែមឡើងឲ្យម្ចាស់រឹតតែក្ដៅក្រហាយឡើងជាងមុន ។

ទ្រង់មានបន្ទូលនេះគាប់ហើយ មើលទៅកម្រនឹងកាប់កម្លាំងពួកបាណ្ឌវបាន ព្រោះប្រទេសតូចធំជាច្រើនរាប់អានគេ តែត្រង់ដែលទ្រង់

ត្រាស់ថា ស្លាប់ទៅជាជាងរស់នៅដោយសេចក្តីអប្បយស នោះជាព្រះតម្រិះដ៏ខុសសោះ សេចក្តីអប្បយសប្រៀបដូចអាកាសធាតុក៏ជាបាន មិនដូចនោះទេ ក៏ដូចជាមុខដំបៅអាចនឹងរក្សាឲ្យសះជាទៅបានក្នុងមិនយូរ សេចក្តីគិតមួយយ៉ាងបានមកដុះឡើងក្នុងចិត្តខ្ញុំ នឹងទូលឲ្យទ្រង់ជ្រាប ដោយឧបាយមួយយ៉ាងឃើញបានការជាប្រាកដ គឺ យុធិស្ឋិរ ចូលចិត្តលេងស្កាមែនដឹងពួកល់គ្នាហើយ ចំណែកឯខ្ញុំទ្រង់ក៏ទ្រង់ជ្រាបហើយ ដែលថា ស្ទាត់ក្នុងការល្បែងស្កា យ៉ាងម្តេច យុធិស្ឋិរ នៅទន់ហត្ថណាស់ ខ្ញុំអាចនឹងលេងយកជ័យជម្នះបានដោយឧបាយតាំងពាន់ផ្លូវ គឺខ្ញុំនឹងលេងដោយកូនស្កាបន្លំសំណរជន្ទរឲ្យបានចិត្តខ្លាំងឡើង ៗ ប្រមាណតែត្រឹមពាក់កណ្តាលឲ្យ ខ្ញុំនឹងធ្វើឲ្យគេហោចទៅតែម្តង នឹងលេងឲ្យអស់សាច់ឈាមទៅតែម្តង នឹងរឹបយកទាល់តែកាន់អម្បែងដើរសុំទាន ឬនឹងតែគាត់ឲ្យតឹងជាងនេះទៅទៀតក៏បាន ដោយសន្យាថា អ្នកចាញ់ត្រូវចេញចាកព្រះនគរទៅនៅព្រៃកំណត់អស់វេលា ១២ ឆ្នាំ យើងអាចនឹងលាងសឹកសត្រូវរបស់យើងឲ្យអបរាជ័យលើងទៅ ដោយគំនិតលែបខាយឧបាយកលខាងក្នុងដូចនេះ មិនមែនចេញមុខច្បាំងគ្នាក្នុងក្បាំងបំផ្លាញគ្រឿងយុទ្ធភណ្ឌទៅទទេៗនោះទេ ។

# ភាគទី ៦

## ការលេងស្កាភ្នាល់យ៉ាងធំ

ឥឡូវនេះទុរយោធន៍នឹងសកុនិ បានរួមគំនិតគិតការត្រៀមទុកព្រមស្រេចហើយ លំដាប់នោះ ទុរយោធន៍ ក៏ចូលទៅគាល់ព្រះរាជបិតា ក្រាបចុះយុគលបាទ ទ្រង់ព្រះកន្សែងអាក់អួលទឹកព្រះនេត្រស្រក់ស្រះ-ស្រាក់ស្រោចកគ្រ្តា ព្រះរាជបិតាឃើញអាការកូនសម្លាញ់ដូចនោះ ក៏ត្រាស់សួរដល់ហេតុផល ។

ព្រះជាម្ចាស់លើត្បូងចូលទ្រង់ជ្រាប សេចក្ដីល្អនៃក្រុងឥន្ទ្របថរបស់យុធិស្ឋិរ ជាជាងហស្តិនបូររបស់យើង ដែលល្បីល្បាញពីណាមកហើយជាច្រើនភាគ ទីព្រះឃ្លាំងរបស់គេពេញទៅដោយ មាស ប្រាក់ កែវកងពេជ្រ និលចិន្តាដ៏មានតម្លៃ រដ្ឋសីមារបស់គេសុទ្ធសឹងតែប្រាសាទប្រូងប្រាង្គប្រាលរន្ទាល ហាក់បីដូចជាយានយឹតយកអំពីស្ថានសួគ៌ មកប្រតិ-ស្ថានទុកនៅទីនោះសម្បត្តិទាំងនេះដើម្បីឡើយយើងជាអ្នកអបលោកឲ្យគេឥឡូវនេះគេរុងរឿងហួសមុខមាត់យើងទៅហើយ គេធ្វើកក្រអឺតក្រទមមើលងាយយើងយ៉ាងអ្នកព្រៃ ព្រះករុណា ទូលព្រះបង្គំខ្ញុំចាំបង់តែស្លាប់បង់ ជាសេចក្ដីពិតតាមប្រមាណមេល ទូលព្រះបង្គំជាខ្ញុំតាមដែលទទួលសេចក្ដីទោមនស្សទាំងនេះ គង់ជាមិនអាចជីវិតរស់នៅរហូតមកបានក្រាបទូលរឿងនេះឲ្យទ្រង់ជ្រាបទេ តែគ្រោះជាទ្រង់ សកុនិ បានជួយ

បន្ទោរទុកអម្បាលនេះបញ្ចេញទៅបានខ្លះ  រាប់ថាជាព្រះគុណយ៉ាងខ្ពស់ ទ្រង់សម្ដែងចំពោះឧបាយកលយ៉ាងឯក  សម្រាប់ទឹងកាច់កិនគួបរប័ក្សប្រគួត ទឹងយើងឲ្យលើងក្នុងទៅ  លេសខនោះ  ទ្រង់ សកុទិ  ឲ្យប្រតិបត្តិដូច នេះ  ឥញ្ជើញយុធស្ដិរមកលេងស្កាក្ដាល់គ្នា  ពួកយើងត្រៀមការប្រេប ហើយ  ដែលទឹងធ្វើឲ្យគេអបរាជ័យកល់ក្ដារទៅ  ត្រាតែទូលព្រះបង្គំជាខ្ញុំ បានរបស់ដែលខូចទៅត្រឡប់មកវិញ  គឺថាទឹងយករាជអាណាក្រពាក់ កណ្ដាល  ដែលចែកទៅឲ្យគេមកវិញ  បើគ្រោះអាក្រក់ទូលព្រះបង្គំជាខ្ញុំ បាញ់គេក៏តាមយថាកម្ម  ទូលព្រះបង្គំជាខ្ញុំសុះបិត្តទទួលបាបគ្រោះកម្ម នោះដោយតុណ្ហីភាព  ឲ្យគេជាព្រះពជាតែមួយអង្គ  ជំនួសទូលព្រះបង្គំ ជាខ្ញុំទាំងអស់ទៅចុះ  ថាបើមិនដូចនោះទេ  គួរឲ្យទូលព្រះបង្គំជាខ្ញុំ បានគ្រង់អាណាចក្រទាំមូល  ដោយមិនទាំបាច់បែងប៉ាន់ឲ្យអ្នកឯណាទីមួយ តែដែលឲ្យធ្វើធំទាំងពីរ  ផ្កាយពីរដួងទឹងបរទៅក្នុងរាសីតែមួយជាមួយគ្នា មិនបានព្រះករុណា ។

ចួតរាស្ត្រគ្រាស់តប  កូនសម្លាញ់ឪពុក  លោកកេតឡើងព្រោះ តោស  ទើបឯតោសនោះសោត  បានទឹងសេចក្ដីកំមួយរំពេចៗប៉ុណ្ណោះ ម្ដេចបានណាយឲ្យក្លែងពិពោធចូលមកដុតពេលហឫទ័យរបស់បាឲ្យក្រៀម ក្រំទៅថ្ងៃ  ម្ដេចបានទើបមកគិតយាយ័បងប្អូនឯងទៀត  គេបានលំបាក តោកយ៉ាកមកក៏ល្អមហើយ  ឲ្យគេនៅជាសុខផងចុះកូន  ការស្វែងរក

រឿងទៅលើអ្នកមានអំណាចនិងសក្តិ ក៏ស្មើដូចជាដាស់រាជសីហដែលដេកលក់ឲ្យភ្ញាក់ អារឿងភ្នាល់បាក់នាំមកនិយាយឲ្យបិតាឮ បិតាស្អប់ឈ្មោះពោះសម្ដែងកំណាស វាប្រាប់ហេតុសេចក្ដីវិនាសនឹងគ្រោះថ្នាក់ប៉ុណ្ណោះ បិតាព្រឺក្បាលកាលមកគិតនឹងអនុញ្ញាតឲ្យបាលេងស្កាភ្នាល់គ្រានេះ តែចូលសួរវិទូរមើល គេនឹងមានសេចក្ដីឃើញដូចម្ដេចក្នុងរឿងនេះ ។

វិទូរ មិនបង្អង់ឲ្យសួរទាន់ ក្រោកឡើងឈរសុំពរវកាសហើយសម្ដែងសេចក្ដីឃើញរបស់គេថាទេវ ព្រះអង្គរមែងទ្រង់ជ្រាបថា ទូលព្រះបង្គំជាខ្ញុំមិនធ្លាប់ជាអ្នកប្រចុចប្រចែងអ្នកណា សម្ដីទូលព្រះបង្គំជាខ្ញុំ ច្រើនតែឲ្យទោសដល់ទូលព្រះបង្គំវិញជាញយៗ គ្រានេះក៏ទៀត ព្រោះលោកថាពាក្យពិតវែងស្វែងទូលព្រះបង្គំតោងសូមពោលតាមមតិរបស់ខ្លួន លោកបិត្តុរបស់ម្ចាស់យើង ដែលទៅដណ្ដើមទ្រព្យសម្បត្តិរបស់បងប្អូនមកជារបស់ព្រះអង្គនោះ ទឹងនាំឲ្យវិនាសទៅឯង លេសដែលទ្រង់គិតបំណងនឹងធ្វើទៅនោះ សុទ្ធតែហាយនកម្ម និងអំណោយផលអាក្រក់គួរខ្លាចណាស់ណា ទូលព្រះបង្គំជាខ្ញុំយល់ឃើញថាជាមុខក្រសួងរបស់ទូលបង្គំជាខ្ញុំ ត្រូវតែក្រាបទូលដាស់តឿនព្រះសតិទ្រង់ព្រះករុណា ។

សេចក្ដីមិនពេញព្រះហឫទ័យឲ្យលេងស្កាភ្នាល់ របស់ព្រះរាជានឹងពាក្យយល់ទាល់របស់វិទូរនេះ មិនធ្វើឲ្យទុរយោធន៍រសាយមនោមានទៅបាន ត្រឡប់ជាធ្វើសេចក្ដីឫស្យាឲ្យចាស់ក្លាឡើង ចំណែកឯយុធិស្ឋិរ

ជាអ្នកប្រកបដោយគុណសម្បត្តិផ្សេង ៗ ក៏មែនតែនៅទន់ ១ យ៉ាងគឺត្រង់សព្វព្រះហឫទ័យលេងស្កា ខនេះជាចារដ៏សំខាន់ ដែលព្រះអង្គមិនអាចទងតស៊ូរបាន ។

កាលទ្រង់ជ្រាបថា មានល្បែងភ្នាល់ស្កានៅទីណា ក៏តែងស្តេចទៅទត ឬទៅលេងជាមួយនឹងគេនៅទីនោះជាដរាប ព្រោះហេតុនោះ កាលទុរយោធន៍អញ្ជើញទៅគ្រសាលេងភ្នាល់ ទ្រង់ឃើញជាកិត្តិយសមួយយ៉ាង គួរនឹងទទួលអញ្ជើញទៅភ្នាល់នឹងគេ ទើបស្តេចចេញចាកឥន្ទ្របថបុរី នាំយកទាំងព្រះអនុជទាំង ៤ នឹងព្រះជនទិដកនឹងទ្រៅបទី ទៅផង ។

បាប់លេងភ្នាល់ស្កា ក្តារដំបូង យុធិស្ឋិរ ចាញ់មួយពាន់ ក្នុងក្តារតៗទៅក៏ទន់ជាងគេជាដរាបក្នុងថ្ងៃគ្រោះមិនល្អនោះ ថ្ងៃព្រឹកឡើងទ្រង់ក្រសាលទៀត ក៏ចាញ់គេទៀត កាលចាញ់ណាស់ទៅ ក៏កើតក្តៅក្រហាយខ្លាំងឡើង ៗ មាស ពេជ្រ សេះ ដំរី រថ ទ្រង់យកមកដាក់ភ្នាល់នឹងគេទៀត របស់ទាំងនេះក៏របូតផុតដៃទៅទៀត លំដាប់នោះទ្រង់យកព្រះរាជទ្រព្យក្នុងព្រះឃ្លាំងមកតាំងភ្នាល់ រួចអំពីនោះទ្រង់យករាជអាណាចក្រ របស់ទាំងពីរមុខនេះក៏រលាយទៅតាមគ្នាដូចមុន ទោះម្ល៉ឹងហើយសេចក្តីក្រហល់ក្រហាយក្នុងការល្បែងក៏មិនមានស្រាក ទ្រង់លើកយកព្រះអនុជទាំង ៤ ទៅតាំងភ្នាល់ អស់ព្រះអនុជទាំង ៤ ដាក់ព្រះអង្គឯងទៀត

ក្នុងទីបំផុតដាក់នាង ទ្រៅបទី ក៏របូតបាត់ស្រមោលទៅទៀត ។ ជាទី
អច្ឆរិយសអាម៉ាស់មុខជាបំផុត ភិស្ម ទោណា និង វិទូរ មើលតែក្នុង
ចិត្តសែនស្តាយសែនសង្វេគវេទនា ចំណែកឯកណ៌ ទុហសាសន និងពួក
អ្នកគិតកោងអប្បល័ក្ខណ៍ទាំងប៉ុន្មាន អគ្គិយលេង ទឹកមុខញញឹម ដោយ
ឃើញផ្លូវបានប្រៀបយ៉ាងធំ ដូចមនោរថហើយ ។

ទីបំផុតដែលកប់ចិត្តឈ្នះបាញ់គ្នា ក៏គិតត្រឹម ទ្រៅបទី ទុរយោធន៍
ត្រាស់ឲ្យ វិទូរ ទៅយកខ្លួននាងមកក្នុងបន្ទប់ទីប្រជុំជួបគ្រូ ដោយទ្រង់
យល់ឃើញថា វេលានេះនាងមិនមែនជាកជិទ នាងធ្លាក់ទៅជាទាសី
ហើយ វិទូរ ក្រាបទូលអង្វរថា សុំព្រះហឫទ័យកុំទ្រង់ធ្វើដល់ម្ល៉ោះ
ដែលទឹងនាំ ទ្រៅបទី មកកាន់ទីនេះ ជាការប្រមាថមើលងាយនាងហួស
សមគួរ ជាហេតុឲ្យពួកបាណ្ឌវបណ្ដាលៈទោស ខ្ពលខ្លាញ់ឡើងទឹងកើត
ហេតុធំ រឿងនេះតែងធ្វើរលោភៈទៅ សូម្បីតែភារកក្នុងប្រទេសឥន្ទ្របថ
ក៏អត់មិនបាន ។

ទុរយោធន៍ពោលពាក្យត្រគោះឲ្យ វិទូរ ជាច្រើន ត្រាស់ឲ្យរាជ
បុរសទៅកោះយកខ្លួននាង ទ្រៅបទី មក វិទូរ ជាអ្នកស្លូតសុចរិតដកតែ
ដង្ហើមធំទឹងគិតតែក្នុងចិត្តថា ទុរយោធន៍បោះបង់ធម្មចរិយាហើយ សេចក្តី
ទុច្ចរិតជាផ្លូវត្រង់ទៅអបាយ ឥឡូវទុរយោធន៍ ក៏កិលទឹងចុះទៅកាន់ផ្លូវ
នោះហើយ ។

គ្រានោះទ្រៅបទីទៅ កំពុងប្រថាប់នៅក្នុងបន្ទប់ បន្តិចរាជបុរស ទៅដល់ បើកទ្វារក្រោកចូលទៅ ទូលប្រវត្តិហេតុដល់នាងតាមព្រះរាជតម្រាស់ ទ្រៅបទី ធ្លាក់ព្រះហឫទ័យក្តុក តែដំកល់សតិសម្បជញ្ញៈទាន់ មានបន្ទូលនឹងសារ័ណទូត អ្នកមកកោះខ្លួន ថាម្នាលនាយ ត្រៀក យើងបានស្តាប់សម្តីអ្នកឯងនិយាយដូចនេះមែនឬ ព្រះរាជស្វាមីត្រាស់នឹងអ្នកដូចនេះឬ(១) ទ្រង់អស់ព្រះរាជទ្រព្យហើយឬ ទើបយករាជិនីទៅដាក់ភ្នាល់នឹងគេ ទ្រង់វិកលព្រះសតិទៅហើយឬ ។

ព្រះរាជទ្រព្យអស់ហើយក្រាបទូល ព្រះចៅ យុធិស្ឋិរ បង់ខាតសព្វសារពើដែលនៅក្នុងសេចក្តីគ្រប់គ្រងរបស់ខ្លួន រហូតដល់មកុដ ព្រះអនុជ ព្រះរាជិនី ។ល។ ទាំងអស់ហើយ ។

ទ្រៅបទី ក្រោកឈរខាងសរទិយដោយតោស,ណា ។

បើព្រះរាជារបស់យើងដាក់ព្រះអង្គជារបស់សម្រាប់ភ្នាល់នឹងគេ អំពីដើមរៀទៅហើយសោត ព្រះអង្គក៏ក្លាយទៅជាទាសៈគេមួយរំពេចទៅហើយ ពន្រឹះតោះមកព្រះអង្គមិនមានអំណាចនឹងមកយកខ្លួនយើងទៅ ដាក់ភ្នាល់ទៀតឡើយ ព្រោះហេតុថាធម្មតាជាតិជាខ្ញុំគេរមែងគ្មានទ្រព្យសម្បត្តិ នឹងមិនមានអំណាចនឹងលក់ដូររបស់អ្វីបាន ព្រោះហេតុនោះ គាត់ចូលនាំ

---

១ ទ្រៅបទី ដំបូងបានជាទេពីអរជុន វេលាក្រោយមកឮថា បានទៅជាទេវីរបស់ព្រះយុធិស្ឋិរ ហើយជារាជិនីប្រទេសឥន្ទ្របទ ។

ពាក្យនេះទៅក្រាបទូលព្រះភស្តារបស់យើងថា គ្មានអ្នកណាមានអំណាចត្រូវបានទ្រៅបទី ។

រាជទូតត្រឡប់ទៅដល់ទីប្រជុំរបស់រដ្ឋមន្ត្រី ក៏នាំសម្តីប្រជួសប្រសោករបស់នាងក្រាបទូលទុរយោធន៍ ទុរយោធន៍ក៏ខ្ញាល់ឡើងដូចភ្លើងអគ្គិសនី ត្រាស់ប្រើទុហសាសនជាអនុជ ឲ្យទៅអូសយកនាងមាតរីងមកគាល់ជាដាច់ ។

ទុហសាសនទៅដល់ដំណាក់ ចូលទៅក្នុងបន្ទប់ទ្រៅបទីថ្លែងព្រះរាជឱង្ការថា ទុក្សត្របញ្ចាលព្រះនាងត្រូវគេយកទៅជាភ្នាល់ ឥឡូវនេះព្រះនាងធ្លាក់ទៅជារបស់នៃអ្នកឈ្នះហើយ សម្តេចព្រះជេដ្ឋាទុរយោធន៍ មានព្រះបន្ទូលឲ្យទៅគាល់ព្រះអង្គ ដែលជាម្ចាស់ម្ចាយរបស់នាង អំពីនេះជាដើមទៅនាងធ្លាក់ទៅជាបាទបរិចារិការបស់ព្រះអង្គហើយ ។

ទ្រៅបទីទេវី បានស្តាប់ពាក្យប្រមាថមើលងាយនេះ ព្រះកាយញ័ររំពប់ ដោយសេចក្តីខ្លាច និងក្រោធក្រៃពេក នាងយកព្រះហស្តបាំងព្រះភក្ត្រមិនឲ្យទុហសាសនឃើញអាការដែលវិការទៅ ព្រះហឫទ័យញ័រតឹកៗ រញ្ជួយទាំងសកលកាយ ខណៈនោះ នាងស្ទុះចេញអំពីកន្លែង ព្យាយាមនឹងរត់ចេញទៅខាងក្រៅ តែទុហសាសនកំណាចអប្រិយក៏ចាប់កន្ត្រាក់កេសារបស់នាងអ្នករន្ធត់អស់អង្គ ហាក់បីដូចជាស្លឹកព្រឹក្សខ្ចីត្រូវព្រះពាយបក់បោកមក អូសយកទៅ បីដូចជាយមបាល

អូសសត្វនេក នាងលុតជង្គង់អង្វរទុហសាសនថា អើអ្នក អ្នកកុំមក ប៉ះពាល់កាយខ្ញុំដោយដៃរបស់អ្នក ដែលមានមន្ទិលជាប់ អ្នកកំរែង ជ្រាបហើយថា សករបស់ស្ត្រីសក្តិសិទ្ធិ សុភាពស្ត្រីកាលមានគ្រឿង តែងកាយរើករយាកដូច្នេះ មិនទៅរកអ្នកដំម្តេចបាន តែទុហសាសន ជាមនុស្សប្រកបដោយនិស្ស័យរបឹងរឹងរុស មិនព្រមស្តាប់ពាក្យនាងអង្វរ គេតបនាងថា នាងមានគ្រឿងបិទបាំងកាយក្តី អាក្រាតកាយក្តី យើង មិនទទួលដឹង នាងត្រូវតែដើរតាមយើងជាដាច់បង្អង់យឺតយូរមិនបាន ។

គ្រានោះទ្រោបទីនោះបមិនស្រួតទឹងទៅ ក៏តាំងទៅទាំងរយីក រយាក សក់របូតរលូតក្រញ៉ាញក្រញ៉ាស់ ព្រោះត្រូវចាប់អូសដោយ កំហល់កំហែង ព្រះនេត្រពេញទៅដោយអស្សុជលស្រក់ស្រោកស្រោច ក៏ក្រោសុតាស្ត្រី ទ្រោបទីទៅដល់ទីចំពោះព្រះភក្ត្រអ្នកធំទាំងឡាយ នាង ក៏អភិប្រាយសុំទោសអ្នកធំជាមុនថា · បពិត្រលោកទាំងឡាយដ៏ចម្រើន សូមលោកឱ្យអភ័យដល់ខ្ញុំដែលបានឈានចូលមកក្នុងទីប្រជុំនេះ ទាំង គ្រឿងស្លៀកពាក់ដ៏មិនគប្បី ។